ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការពន្យារពេលផ្តល់របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ របស់ រ.ទ.ស.ភ ដែលត្រូវផ្តល់ជូនគណៈកម្មការមូលបត្រកម្ពុជា យ៉ាងយូរត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ នឹងត្រូវពន្យារពេលរហូតដល់ **ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០**។ ដោយមូលហេតុ រ.ទ.ស.ភ មានការយឺតយ៉ាវក្នុងការផ្តល់នូវ Management Accounts ជូនក្រុមហ៊ុន ប៊ីឌីអូ (ខេមបូឌា) លីមីធីត ដែលជាសវនករឯករាជ្យ។ ការយឺតយ៉ាវនេះបណ្តាលមកពី៖

(១) ករណីចុងឆ្នាំ២០១៩ មានការប្រែប្រួលតម្លៃលក់ទឹកថ្មី ធ្វើឱ្យការរៀបចំរបាយការណ៍ និងឯកសារនានារអាក់រអួលបន្តិច។

(២) ការកត់ត្រាចំណូលបង្គរពាក់ព័ន្ធនឹងការប៉ាន់ស្មានវិក្កយបត្រថ្លៃប្រើប្រាស់ទឹកស្អាតនាចុងឆ្នាំ២០១៩។

ដោយហេតុការណ៍ខាងលើនេះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របស់ រ.ទ.ស.ភ ។ ដោយសារការអវត្តមាននៃរបាយការណ៍ហិរញ្ញវត្ថុ ជាផ្នែកសំខាន់នៃរបាយការណ៍ពេញលេញ ហេតុដូចនេះធ្វើឱ្យការរៀបចំរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ របស់ រ.ទ.ស.ភ ក៏មានភាពយឺតយ៉ាវផងដែរ។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបដោយក្តីអនុគ្រោះ។

ថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh